**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**

លេខៈ **០៣(ណា)/៧១៩**
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៤០
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខៈ ៦៤៣
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅ សាលសវនាការលេខៈ ខ១ អគារខ នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ វេលាព្រឹក ដែលមានសមាសភាពចូលរួមដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជី

**ជំនុំជម្រះលើ៖** សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៤០ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២

- **ជនជាប់ចោទ៖** ឈ្មោះ [redacted] **សំអូន** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តឧត្តរមានជ័យ ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តសៀមរាប មុខរបរ កម្មករសំណង់ កំរិតវប្បធម៌ ថ្នាក់ទី០៨ ប្រពន្ធឈ្មោះ [redacted] **ស្រីក្លួង** ឪពុកឈ្មោះ [redacted] សេង (ស) ម្តាយឈ្មោះ [redacted] **សុផាត** (ស) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។ **(ក្នុងឃុំ)**

ជាប់ចោទពីបទៈ "**ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស**" ប្រព្រឹត្តនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

- **មេធាវីការពារសិទ្ធិជនជាប់ចោទ៖** ឈ្មោះ [redacted] អាសយដ្ឋានផ្ទះលេខៈ អ្ខូ៧ ផ្លូវលេខៈ ២៦៥ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

- **ដើមបណ្តឹងរដ្ឋប្បវេណី៖** ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិកសិកម្ម ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន ភូមិកសិកម្ម ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប មុខរបរ បុគ្គលិកលាយស៊ីម៉ង់ ឪពុកឈ្មោះ [redacted] ភេម ម្តាយឈ្មោះ [redacted] សាវេត ប្រវត្តិនៃការផ្តន្ទាទោសពីមុន **គ្មាន** ។

**បានឃើញៈ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ៥២៨ អយធ/២២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

**បានឃើញ:** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣៥៧២ ពស.ព្រស "ឃ" ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

**បានឃើញ:** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: **៦១៥ ពស.ព្រជ(ក)** ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

**អង្គហេតុកើតមានឡើងដូចតទៅ:**

កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង ០០នាទី មានករណីហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស នៅចំណុចភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប បង្កឡើងដោយជនសង្ស័យ ឈ្មោះ [redacted] **សំអូន** ភេទប្រុស អាយុ ៣៥ឆ្នាំ បានធ្វើសកម្មភាពយកកាំបិតប៉័ងតោកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ ៤០ឆ្នាំ ចំក្បាលផ្នែកខាងឆ្វេង បណ្តាលឲ្យរយាស់ហូរឈាម ។ ភ្លាមនោះក្រុមគ្រួសាររបស់ជនរងគ្រោះ បានបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យដេរចំនួន ១៥ថ្នេរ ។ ចំណែកឈ្មោះ [redacted] **សំអូន** ក្រោយពីធ្វើសកម្មភាពរួច បានរត់គេចខ្លួនបាត់ ។ រហូតដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ជនរងគ្រោះបានដាក់ពាក្យបណ្តឹង នៅប៉ុស្តិ៍នគរបាលសង្កាត់ស្រង៉ែ ហើយសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនបានឈ្មោះ [redacted] **សំអូន** តែម្តង ។ តាមចម្លើយរបស់ឈ្មោះ [redacted] **សំអូន** បានសារភាពថា ខ្លួនពិតជាបានកាប់ទៅលើឈ្មោះ [redacted] **សុជាតិ** ពិតប្រាកដមែន ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] **សំអូន** បានឆ្លើយថា៖ ខ្លួនបានកាប់ឈ្មោះ [redacted] **សុជាតិ** ពិតប្រាកដមែន ដោយសារតែឈ្មោះ [redacted] **សុជាតិ** ជេរខ្លួន ។ ខ្លួនខ្វះការពិចារណា រួចក៏បានយកកាំបិតប៉័ងតោកាប់លើឈ្មោះ [redacted] **សុជាតិ** មួយកាំបិត ហើយក៏ដើរចេញទៅ ។ លុះព្រឹកឡើង ខ្លួនក៏ត្រូវបានប៉ូលីសឃាត់ខ្លួនតែម្តង ។

- អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុជាតិ** នៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា៖ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង១៧ និង០០នាទី ខ្លួនបានឈប់សម្រាកពីការងារ រួចជិះម៉ូតូត្រឡប់មកផ្ទះនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។ ពេលជិះម៉ូតូមកដល់ផ្ទះ វេលាម៉ោង ១៧ និង ៣០ នាទី ខ្លួនឈប់ម៉ូតូ រួចហើយបានឃើញម្តាយ និងប្អូនបង្កើតរបស់ខ្លួន ។ បន្ទាប់ពីឃើញម្តាយរបស់ខ្លួន រូបខ្លួនបាននិយាយប្រាប់ទៅម្តាយរបស់ខ្លួនថា មិនបាច់ប្រើគេទៀតទេ ។ មួយសន្ទុះក្រោយមក ស្រាប់តែបានឃើញឈ្មោះ [redacted] **សំអូន** ភេទប្រុស អាយុ ៣៥ឆ្នាំ ត្រូវជាប្អូនថ្លៃ រូបគេបានបើកគោយន្តកៃច្នៃដឹកឈើមកដល់ផ្ទះ ហើយឈប់គោយន្តមិនបានពន្លត់គោយន្តនោះទេ ហើយខ្លួន បាននិយាយប្រាប់ថា មិនឲ្យបងប្អូនអ្នកណាទៅដឹកឈើទៀតទេ បើឪពុកធ្វើមិនកើត ចាំខ្លួនទៅដឹកឈើ ខ្លួនឯង ព្រោះគេជាប់រវល់ធ្វើផ្ទះខ្លួនគេដែរ ។ បន្ទាប់មក រូបខ្លួនបានដើរទៅឈរជិតគោយន្តដឹកឈើ ។ ភ្លាមនោះ ស្រាប់តែឃើញឈ្មោះ [redacted] **សំអូន** បានយកកាំបិតប៉័ងតោពណ៌ស កាប់មកលើខ្លួនចំនួន ០១កាំបិត ចំក្បាលខាងឆ្វេង ផ្នែកខាងក្រោយ បណ្តាលឲ្យមុតហូរឈាមយ៉ាងខ្លាំង។ បន្ទាប់ពីឈ្មោះ [redacted] **សំអូន** កាប់រូបខ្លួនរួចពុំដឹងគេរត់គេចខ្លួនទៅណាទេ រីឯរូបខ្លួនបានរត់ទៅយកក្រម៉ារុំរបួស រួចឲ្យបងប្អូនដឹកខ្លួនទៅមន្ទីរពេទ្យ ដើម្បីព្យាបាលរបួស ។ ពេលនេះ ខ្លួនសុំដកពាក្យបណ្តឹង ឈប់ប្តឹងឈ្មោះ [redacted] **សំអូន** វិញហើយ ដោយហេតុថា ឈ្មោះ [redacted] **សំអូន** បានដឹងពីកំហុសរបស់ខ្លួន បានសុំទោសខ្លួន និងបានសន្យាជាមួយខ្លួនថា ឈប់ធ្វើអំពើបែបនេះទៀតហើយ និងកែខ្លួនឡើងវិញ ។ ហើយរបួសខ្លួន ក៏មិនធ្ងន់ធ្ងរអ្វីដែរ ពេលនេះបានជាសះស្បើយវិញ

អស់ហើយ ។ ខ្លួនសុំឲ្យតុលាការមេត្តាជួយដោះលែងឈ្មោះ [redacted] សំអូន ដែលជាប្អូនថ្លៃរបស់ខ្លួន ដើម្បីបានទៅប្រកបរបរចិញ្ចឹមគ្រួសារវិញផង ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] កេម បានឆ្លើយបំភ្លឺថា៖ ខ្លួនជាឪពុកក្មេករបស់ឈ្មោះ [redacted] សំអូន ។ ខ្លួនសុំរក្សាចម្លើយនៅប៉ូលីសដដែល ។ ពីមុនឈ្មោះ [redacted] សំអូន មិនដែលធ្វើឲ្យមានបញ្ហានៅផ្ទះទេ ទើបតែនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ ឈ្មោះ [redacted] សំអូន ស្រវឹង ទើបមានបញ្ហានេះកើតឡើង ។ ខ្លួនសុំឲ្យតុលាការជួយដោះលែងកូនប្រសារខ្លួនវិញ ដើម្បីរកស៊ីចិញ្ចឹមប្រពន្ធកូនវិញ ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] ស្រីភួង បានឆ្លើយបំភ្លឺថា ខ្លួនជាប្រពន្ធរបស់ឈ្មោះ [redacted] សំអូន ។ ខ្លួនសុំរក្សាចម្លើយនៅប៉ូលីសដដែល ។ ខ្លួនសុំឲ្យតុលាការជួយដោះលែងប្ដីខ្ញុំវិញ ដើម្បីរកចិញ្ចឹមគ្រួសារវិញ ។

- តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ៖ ឆ្លងតាមការពិភាក្សាដេញដោល, ការស្ដាប់ចម្លើយរបស់ជនជាប់ចោទ និង ភស្តុតាងនានា ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរដដែល និង សុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់កំណត់ ។

- មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនបានទទួលស្គាល់ថា កូនក្ដីខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ប៉ុន្តែ ដោយសារតែកូនក្ដីខ្លួនបានសហការជាមួយតុលាការ មិនគេចវេះ ហើយបានសារភាពដោយស្មោះត្រង់ ។ សំណូមពរឲ្យតុលាការផ្ដល់នូវស្ថានសម្រាលទោស ដោយស្នើសុំឲ្យតុលាការអនុវត្តការដាក់ទោសព្យួរលើកូនក្ដីខ្លួន ។

- ជនជាប់ចោទឈ្មោះ [redacted] សំអូន ធ្វើសំណូមពរចុងក្រោយ៖ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង និង សុំឲ្យតុលាការដោះលែងនៅក្រៅឃុំ ដើម្បីរកប្រាក់ចិញ្ចឹមប្រពន្ធ ។

**ក្រោយពីបានពិនិត្យ និង ពិចារណាអង្គហេតុ ភស្តុតាង និង សំណូមពររបស់ភាគី**

**សំអាងហេតុ**

**១/-យល់ឃើញថា៖** ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ៣៥៧២ (ឃ)/ពស.ព្រស ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សម្រេចចោទប្រកាន់ជនជាប់ចោទឈ្មោះ សេង **សំអូន** ភេទប្រុស អាយុ ៣៥ឆ្នាំ (ដូចមានសាវតាជាតិខាងលើ) ពីបទ៖ "**ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស**" ប្រព្រឹត្តនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

**២/-យល់ឃើញថា៖** មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌចែងថា៖ អំពើហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើហិង្សានេះបានប្រព្រឹត្ត៖ ១-ដោយមានការគិតទុកជាមុន ។ ២-ដោយប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ ។ ៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត និង អ្នកសមគំនិត ។

**៣/-យល់ឃើញថា៖** តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជាតិ នៅដំណាក់កាលអយ្យការ និង ដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា៖ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៧ និង ០០ នាទី ខ្លួនបានឈប់សំរាកពីការងារ រួចជិះម៉ូតូត្រឡប់មកផ្ទះនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុង

សៀមរាប ខេត្តសៀមរាប ។ ពេលជិះម៉ូតូមកដល់ផ្ទះ វេលាម៉ោង ១៧ និង ៣០ នាទី ខ្លួនឈប់ម៉ូតូ រួចហើយបានឃើញម្ដាយ និង ប្អូនបង្កើតរបស់ខ្លួន ។ បន្ទាប់ពីឃើញម្ដាយរបស់ខ្លួន រូបខ្លួនបាននិយាយប្រាប់ ទៅម្ដាយរបស់ខ្លួនថា មិនបាច់ប្រើគេទៀតទេ ។ មួយសន្ទុះក្រោយមកស្រាប់តែបានឃើញឈ្មោះ [redacted] **សំអូន** ភេទប្រុស អាយុ ៣៥ឆ្នាំ ត្រូវជាប្អូនថ្លៃបានបើកគោយន្តកែច្នៃដឹកឈើមកដល់ផ្ទះ ហើយ ឈប់គោយន្តមិន បានពន្លត់គោយន្តនោះទេ ហើយខ្លួនបាននិយាយប្រាប់ថា មិនឲ្យបងប្អូនអ្នកណាទៅដឹកឈើទៀតទេ បើឪពុកធ្វើមិនកើតចាំខ្លួនទៅដឹកឈើខ្លួនឯង ព្រោះគេជាប់រវល់ធ្វើផ្ទះខ្លួនគេដែរ ។ បន្ទាប់មករូបខ្លួនបានដើរទៅឈរជិតគោយន្តដឹកឈើភ្លាម នោះស្រាប់តែឃើញឈ្មោះ [redacted] **សំអូន** បានយកកាំបិតប៉័ងតោពណ៌ស កាប់មកលើខ្លួន ចំនួន ០១ កាំបិត ចំក្បាលខាងឆ្វេង ផ្នែកខាងក្រោយបណ្ដាលឲ្យមុតហូរឈាមយ៉ាងខ្លាំង ។ បន្ទាប់ពីឈ្មោះ [redacted] **សំអូន** កាប់រូបខ្លួនរួច ពុំដឹងគេរត់គេចខ្លួនទៅណាទេ រីឯរូបខ្លួនបានរត់ទៅយកក្រម៉ារុំរបួស រួចឲ្យបងប្អូនដឹកឡានទៅមន្ទីរពេទ្យ ដើម្បីព្យាបាលរបួស ។ ពេលនេះខ្លួនសុំដកពាក្យបណ្ដឹងឈប់ប្ដឹងឈ្មោះ [redacted] **សំអូន** វិញហើយ ដោយហេតុថា ឈ្មោះ [redacted] **សំអូន** បានដឹងពីកំហុសរបស់ខ្លួន បានសុំទោសខ្លួន និងបានសន្យាជាមួយខ្លួនថា ឈប់ធ្វើអំពើបែបនេះទៀតហើយ និង កែខ្លួនឡើងវិញ ។ ហើយរបួសខ្លួនក៏មិនធ្ងន់ធ្ងរអ្វីដែរ ពេលនេះបានជាសះស្បើយវិញ អស់ហើយ ។ ខ្លួនសុំឲ្យតុលាការមេត្តាជួយដោះលែងឈ្មោះ [redacted] **សំអូន** ដែលជា ប្អូនថ្លៃរបស់ ខ្លួន ដើម្បីបានទៅប្រកបរបរចិញ្ចឹមគ្រួសារវិញផង ។

**៤/-យល់ឃើញថា៖** តាមចម្លើយសាក្សីឈ្មោះ [redacted] **ភេម** បានឆ្លើយបំភ្លឺថា: ខ្លួនជាឪពុកក្មេករបស់ឈ្មោះ [redacted] **សំអូន** ។ ពីមុនឈ្មោះ [redacted] **សំអូន** មិនដែលធ្វើឲ្យមានបញ្ហានៅផ្ទះទេ ទើបតែនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ ឈ្មោះ [redacted] **សំអូន** ស្រវឹង ទើបមានបញ្ហានេះកើតឡើង ។ ខ្លួនសុំឲ្យតុលាការជួយដោះលែងកូនប្រសារខ្លួនវិញ ដើម្បីរកស៊ីចិញ្ចឹមប្រពន្ធកូនវិញ ។

**៥/-យល់ឃើញថា៖** តាមចម្លើយសាក្សីឈ្មោះ [redacted] **ស្រីក្លូង** បានឆ្លើយបំភ្លឺថា: ខ្លួនជាប្រពន្ធរបស់ឈ្មោះ **សេង សំអូន** ។ ខ្លួនសុំឲ្យតុលាការជួយដោះលែងប្ដីខ្ញុំវិញ ដើម្បីរកចិញ្ចឹមគ្រួសារវិញ ។

**៦/-យល់ឃើញថា៖** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអូន** បានឆ្លើយបំភ្លឺថា: ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ ពេលនោះខ្លួនបាន មកពីដឹកឈើឲ្យឪពុកក្មេក ដោយជិះគោយន្តទាំងស្រវឹងស្រាស្រៀងៗ ។ មកដល់ផ្ទះភ្លាម ស្រាប់តែបងថ្លៃខ្លួនឈ្មោះ [redacted] **សុជាតិ** បានជេរខ្លួនដោយពុំដឹងមូលហេតុ ភ្លាមនោះខ្លួនបានចូលផឹក ស្រាប់តែគាត់នៅតែជេររហូត ភ្លាមនោះ ស្រាប់តែខ្លួន ខ្វះការពិចារណាក៏បានទាញកាំបិតប៉័ងតោតូច មកកាប់បងថ្លៃឈ្មោះ [redacted] **សុជាតិ** ត្រូវក្បាលបែកបន្តិច ។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាខុសមែន និង ដឹងកំហុសគ្រប់យ៉ាង ។ ខ្លួនពុំដែលមានជម្លោះ ជាមួយបងថ្លៃឈ្មោះ [redacted] **សុជាតិ** ទេ ។ ពេលកើតហេតុខ្លួនមិនរត់គេចអ្វីទេ គឺដើរទៅផ្ទះបងដែលជិតនោះដើម្បីឲ្យរឿងរ៉ាវចប់សិន ។ ខ្លួនសូម សំណូមពរឲ្យតុលាការជួយបន្ធូរបន្ថយឲ្យខ្លួនផង និងសុំឲ្យតុលាការដោះលែងនៅក្រៅឃុំ ដើម្បីរកប្រាក់ចិញ្ចឹមប្រពន្ធ ។

**៧/-យល់ឃើញថា៖** ចម្លើយរបស់ជនរងគ្រោះ និង ជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុជាតិ** និង ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអូន** នៅដំណាក់កាលស៊ើបអង្កេត ដំណាក់កាលស៊ើបសួរ និង អំឡុងពេលសវនាការរួមទាំងភស្តុតាងផ្សេងទៀតដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នា និង គ្មានមន្ទិលសង្ស័យ ដែលតុលាការយល់ឃើញថា កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ នៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ជនជាប់ចោទឈ្មោះ [redacted] **សំអូន** ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសទៅលើជនរងគ្រោះ និង ជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុជាតិ** ប្រាកដមែន ។

៨/-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សំអូន គឺជានីតិជន មានសមត្ថភាពយល់ដឹង និង ស្មារតីល្អ អាចវិនិច្ឆ័យអំពីអំពើ និង លទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួន ។ ជនជាប់ចោទមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើ ដែលខ្លួនបានប្រព្រឹត្ត ។

៩/-យល់ឃើញថា៖ ជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជាតិ បានសុំដកពាក្យបណ្តឹងឈប់ប្តឹងឈ្មោះ [redacted] សំអូន វិញហើយ ដោយហេតុថា ឈ្មោះ [redacted] សំអូន បានដឹងពីកំហុសរបស់ខ្លួន ហើយបានសុំទោសខ្លួន និង បានសន្យាជាមួយខ្លួនថា ឈប់ធ្វើអំពើបែបនេះ ទៀតហើយ និង កែខ្លួនឡើងវិញ ។ ហើយរបួសខ្លួន ក៏មិនធ្ងន់ធ្ងរអ្វីដែរ ពេលនេះបានជាសះស្បើយវិញអស់ហើយ ។ ដូច្នេះ គប្បីតុលាការ មិនសម្រេចលើសំណងផ្នែករដ្ឋប្បវេណីឡើយ ។

១០/-យល់ឃើញថា៖ តាមចម្លើយសារភាពរបស់ជនជាប់ចោទ បង្ហាញឲ្យឃើញថា ជនជាប់ចោទទើបតែប្រព្រឹត្តអំពើល្មើសនេះលើកដំបូង និង មានស្មារតីភ្ញាក់រលឹកចេះទទួលស្គាល់កំហុស ។ ម្យ៉ាងវិញទៀតព្យសនកម្ម នៃអំពើល្មើសនេះមានលក្ខណៈតិចតួចមិនធ្ងន់ធ្ងរ ហើយចរិតនៃអំពើល្មើសក៏មិនប៉ះពាល់ធ្ងន់ដល់សង្គមខ្លាំងដែរ ។ ដូច្នេះ គប្បីតុលាការសម្រេចផ្តន្ទាទោស ជនជាប់ចោទ ត្រឹមកម្រិតអប្បបរមា ។

១១/-យល់ឃើញថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំអូន ពីបទៈ **"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស"** ប្រព្រឹត្តនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។ គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សំអូន តាមច្បាប់ ។

១២/-យល់ឃើញថា៖ ចំពោះវត្ថុតាងពាក់ព័ន្ធនឹងបទល្មើស រួមមាន កាំបិតប៉ុងតោ ចំនួន ០១ (មួយ) ដែលជាមធ្យោបាយ ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស ។

**<u>ហេតុដូច្នេះសម្រេច</u>**

**១**/-ផ្តន្ទាទោស ឈ្មោះ [redacted] **សំអូន** ភេទ ប្រុស អាយុ ៣៥ឆ្នាំ (មានសាវតាដូចខាងលើ) ដាក់ពន្ធនាគារ កំណត់រយៈពេល **២** (**ពីរ**) ឆ្នាំ ពីបទ **"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស"** ប្រព្រឹត្តនៅភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**២**/- រឹបអូសវត្ថុតាង រួមមាន កាំបិតប៉ុងតោ ចំនួន ០១ (មួយ) ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅសៀមរាប, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]